**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ២៩៩.....សហវ.ពក.

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបង្កើត និងកិច្ចដំណើរការអន្តរភាពគ្រប់គ្រងតម្លៃបម្លែងការនៃទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៦៣ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានផែនការបច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បានឃើញប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើតអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលដឹកនាំដោយមន្ត្រីរាជការគយនិងរដ្ឋាករដូចតទៅ ៖

| | | |
|---|---|---|
| ១- លោក **គុណ ញឹម** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- លោក **ម៉ែន សំអាន** | ប្រធានលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | អនុប្រធាន |
| ៣- លោក **នួន ច័ន្ទរិទ្ធ** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **ម៉ុរ ម៉ុនណារ៉ា** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៥- លោក **សុខ សុទិន្នា** | អនុប្រធានទទួលបន្ទុករួមការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៦- លោក **រស់ ដារ៉ា** | អនុប្រធានទទួលបន្ទុករួមការិយាល័យផែនការ គោលនយោបាយ | សមាជិក |
| ៧- លោក **សង់ ស៊ីណារិទ្ធ** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៨- លោកស្រី **ហោខ សំអួន** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៩- លោក **ជួន ម៉ូលីន** | ជំនួយការការិយាល័យលេខាធិការ និងជំនួយការ | សមាជិក |

**ប្រការ ២.-**

អង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ត្រូវបានបែងចែកជា ៣ ក្រុមការងារ ដែលមានភារកិច្ចគ្រប់គ្រងការវាយតម្លៃចម្លងការនៃទំនិញនាំចូល ដូចតទៅ ៖

ក្រុមការងារទី ១ ៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ១ ដល់ជំពូក ២៧ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករដូចខាងក្រោម ៖

| | |
|---|---|
| ១- លោក **រស់ ដារ៉ា** | ប្រធាន |
| ២- លោកស្រី **ហោខ សំអួន** | អនុប្រធាន |
| ៣- លោក **ជួន ម៉ូលីន** | អនុប្រធាន |
| ៤- លោក **តាំ ច័ន្ទកុសល** | សមាជិក |
| ៥- លោក **កែវ ស៊ីន** | សមាជិក |
| ៦- លោក **ម៉ាក់ ចិសាល** | សមាជិក |

៧- លោក **ណៅ សុណាង** សមាជិក

៨- លោក **ឯម វុ៉ន្នី** សមាជិក

៩- លោកស្រី **ជាស័ក្តិ ថាវិរី** សមាជិក

ក្រុមការងារទី ២ ៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ៦៨ ដល់ជំពូក ៨៤ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

១- លោក **សុខ សុទិន្នា** ប្រធាន

២- លោក **ម៉ុក ហួត** អនុប្រធាន

៣- លោក **ប៉ោ សួន** អនុប្រធាន

៤- លោក **អ៊ុង ជាំខេង** សមាជិក

៥- លោកស្រី **ប៉ែន ច័ន្ទសច្ចារ** សមាជិក

៦- លោក **ឆួច លីដែល** សមាជិក

៧- លោក **ឈន ចិត្រា** សមាជិក

៨- លោកស្រី **គីម ណាលី** សមាជិក

៩- លោក **អោះ និច្ច** សមាជិក

ក្រុមការងារទី ៣៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ៨៥ ដល់ជំពូក ៩៨ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

១- លោក **ម៉ូរ ម៉ុនណារ៉ា** ប្រធាន

២- លោក **សង់ ស៊ីណារិទ្ធ** អនុប្រធាន

៣- លោក **ស្រេង សំណាង** អនុប្រធាន

៤- លោក **អ៊ុច តាំងតា** សមាជិក

៥- លោក **ជា សំណាង** សមាជិក

៦- លោក **លឹម អេង** សមាជិក

៧- លោក **ស៊ីផុន ស៊ីថានា** សមាជិក

៨- លោក **សាយ សុផា** សមាជិក

៩- លោក **យ៉ឹក យូ** សមាជិក

**ប្រការ ៣.-**

អង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូលនេះ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងការងារស្រាវជ្រាវ និងលើកសំណើគោលនយោបាយតម្លៃគិតពន្ធគយ ស្របតាមបញ្ញត្តិច្បាប់ជាធរមាន ឈានទៅធានាឲ្យបាននូវអនុលោមភាពរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីតាកផពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ ១៩៩៤ របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)
- លើកឡើងនូវផែនការសកម្មភាព ការកំណត់អាទិភាព និងវិសាលភាពនៃការអនុវត្តតាមវាក្យខ័ណ្ឌ ១ នៃប្រការនេះ រួមបញ្ចូលទាំងការងារវិមជ្ឈការ ប្រតិបត្តិការកំណត់ ឬផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ឲ្យបានស្របតាមបញ្ញត្តិប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល និងតាមបទប្បញ្ញត្តិជាធរមានផ្សេងទៀត
- សម្របសម្រួលជាមួយនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ និងនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីធានាឲ្យបាននូវភាពស៊ីចង្វាក់នៃការកសាងគោលនយោបាយ និងអនុលោមភាពលើទិដ្ឋភាពច្បាប់ និងបច្ចេកទេស
- សម្របសម្រួលជាមួយផ្នែកឯកជនពាក់ព័ន្ធក្នុងភាពជាដៃគូ ធានាឲ្យបាននូវការចូលរួមតាមរូបភាពផ្សេងៗក្នុងការពិគ្រោះយោបល់ ក្នុងករណីយល់ថាចាំបាច់ ដើម្បីកសាងមូលដ្ឋានទិន្នន័យតម្លៃចម្លងការនៃទំនិញ សម្រាប់ជាមូលដ្ឋានសំខាន់បំផុតលើការកំណត់តម្លៃគិតពន្ធគយ ។ ការងារនេះអាចដំណើរការតាមរយៈយន្តការ "ភាពជាដៃគូគយ-ផ្នែកឯកជន" Customs-Private Sector Partnership – CPSP តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀត ក្នុងគោលបំណងធានានូវវិភាពនៃការកំណត់តម្លៃគិតពន្ធគយតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ក្រុមការងារស្រាវជ្រាវតម្លៃចម្លងការនៃទំនិញនាំចូល ដូចមានចែងក្នុងបញ្ញត្តិប្រការ ២ នៃប្រកាសនេះ មានភារកិច្ចដូចតទៅ ៖

- ស្រាវជ្រាវ តាមដានជាប្រចាំនូវការវិវត្តតម្លៃចម្លងការនៃទំនិញនាំចូល ពីពេលមួយទៅពេលមួយ ដោយអនុលោមតាមបញ្ញត្តិប្រការ ៥ នៃប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ព្រមទាំងបញ្ញត្តិមាត្រា ២១ និង ២២ នៃច្បាប់ស្តីពីគយ ដោយប្រើប្រាស់ទិន្នន័យមានស្រាប់ ក្នុងរបាយការណ៍ជាក់ស្តែងនានា ទិន្នន័យស្រង់ចេញពីកិច្ចបញ្ជីការគណនេយ្យពាក់ព័ន្ធនឹងតម្លៃទំនិញរបស់បុគ្គលផ្សេងៗ និងពីប្រភពទិន្នន័យផ្សេងទៀត សម្រាប់ជាមូលដ្ឋានពិចារណាបន្ថែម ដូចជាតម្លៃទំនិញលើគេហទំព័រ ប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយនានាដែលអាចរកបាន /

ធ្វើរបាយការណ៍ប្រចាំខែ ពីលទ្ធផលការងាររបស់ខ្លួន ជូនអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ដូចមានចែងក្នុងបញ្ញត្តិប្រការ ១ នៃប្រកាសនេះ

កសាង និងកែសម្រួលរៀងរាល់ដំណាច់ខែនីមួយៗ នូវតារាងតម្លៃចម្លងការនៃទំនិញសម្រាប់ពិចារណា (Transactional Value List for Consideration) លើមុខទំនិញដែលស្ថិតក្នុងមុខសញ្ញាគ្រប់គ្រងរបស់ខ្លួន ដូចមានចែងក្នុងបញ្ញត្តិប្រការ ២ នៃប្រកាសនេះ សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ដែលបានប្រកាសដោយធុរជន ឲ្យបានឆាប់រហ័ស និងស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ព្រមទាំងធានាឲ្យបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ និងអាករគយ

- អនុវត្តភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

មន្ត្រីរាជការគយនិងរដ្ឋាករដូចមានរាយនាមក្នុងបញ្ញត្តិប្រការ ១ និងប្រការ ២ នៃប្រកាសនេះ ត្រូវបំពេញភារកិច្ចតាមបញ្ញត្តិនៃប្រកាសនេះបន្ថែមលើមុខងារបច្ចុប្បន្ន ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ